ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៤ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៨-១-១៩៩៩ - ព្រះរាជក្រឹត្យលេខ ០១៩៩/០៧ នស/រកត ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ ១១០

II- ធីស្តីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១០ អនក្រ ស្តីពីការបង្កើតខុទ្ទកាល័យស៊ីវិល ខុទ្ទកាល័យ យោធា និងនាយកដ្ឋាន ចំណុះក្រសួងការពារជាតិ ១១២

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១១ អនក្រ ស្តីពីការប្តូរទីរួមខេត្តជាស្រុក និង សង្កាត់ ឃុំ ក្នុងខេត្ត កំពង់ចាម ១១៥

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១២ អនក្រ ស្តីពីការប្តូរឈ្មោះស្រុកទីរួមខេត្ត សង្កាត់ ក្នុងខេត្ត រតនគិរី ១១៦

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១៣ អនក្រ ស្តីពីការប្តូរទីរួមខេត្តជាស្រុក និង ឈ្មោះ សង្កាត់ក្នុងខេត្ត ស្ទឹងត្រែង ១១៧

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១៤ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត កំពត ១១៨

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១៥ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុង ខេត្ត ព្រៃវែង ១២១

២៧-១-១៩៩៩ -អនុក្រឹត្យលេខ ១៦ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត តាកែវ ១២២

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ១៧ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត បន្ទាយមានជ័យ ១២៣

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ១៨ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ឃុំ ក្នុងខេត្ត កំពង់ឆ្នាំង ១២៤

២៧-១-៩៥ -អនុក្រឹត្យលេខ ១៩ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តមណ្ឌលគិរី ១២៥

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២០ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត ព្រះវិហារ ១២៦

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២១ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត កោះកុង ១២៧

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២២ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តពោធិសាត់ ១២៨

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៣ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តកំពង់ស្ពឺ ១៣០

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៤ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត សៀមរាប ១៣១

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៥ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តបាត់ដំបង ១៣៣

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៦ អនក្រ ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្ត កំពង់ធំ ១៣៤

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៧ អនក្រ ស្តីពីការប្តូរឈ្មោះស្រុកទីរួមខេត្ត សង្កាត់ក្នុងខេត្តស្វាយរៀង ១៣៥

២៧-១-១៩៩៥ -អនុក្រឹត្យលេខ ២៨ អនក្រ ស្តីពីការប្តូរឈ្មោះស្រុកទីរួមខេត្ត សង្កាត់ ក្នុងខេត្ត កណ្តាល ១៣៧

២៨-១-១៩៩៥ -អនុក្រឹត្យលេខ ០៦ អនក្រ ស្តីពីការតែងតាំងមន្ត្រី រាជការ ១៣៧

២៥-១-១៩៩៥ -អនុក្រឹត្យលេខ ០៧ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣៧
២៦-១-១៩៩៥ -អនុក្រឹត្យលេខ ០៨ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣៨
២៦-១-១៩៩៥ -អនុក្រឹត្យលេខ ០៩ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ........ ១៣៩
២៧-១-១៩៩៥ -អនុក្រឹត្យលេខ ១០ អនក្រ ស្តីពីការតែងតាំងមន្ត្រី រាជការ........ ១៤០
២៧-១-១៩៩៥ -អនុក្រឹត្យលេខ ១១ អនក្រ ស្តីពីការតែងតាំងមន្ត្រី រាជការ........ ១៤១
៣០-១-១៩៩៥ - អនុក្រឹត្យលេខ ១២ អនក្រ ស្តីពីការតែងតាំងមន្ត្រី រាជការ........ ១៤២
៣០-១-១៩៩៥ -អនុក្រឹត្យលេខ ១៣ អនក្រ ស្តីពីការអោយចូលនិវត្តន៍មន្ត្រី រាជការ ១៤៣

២.សេចក្ដីសំរេច

២៥-១-១៩៩៥ -សេចក្តីសំរេច លេខ ១៣ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន ១៤៤
២៧-១-១៩៩៥ -សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៤៥

III- ភារខារបណ្ដាក្រសួខ

១.ធីស្ដីភាររដ្ឋមន្ត្រីក្រសួខឧស្សាហាកម្ម រ៉ែ និខ ថាមពល

ប្រកាស

២៦-១-១៩៩៥ -ប្រកាសលេខ ៦០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ង៉ែង សៀកលាង ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មច្នៃត្បូង ១៤៦
២៦-១-១៩៩៥ -ប្រកាសលេខ ៦១ ផក.ប្រក អនុញ្ញាតអោយលោក ច័ន្ទ គៀន ជនជាតិខ្មែរ បើកដំណើរការឡចំហុយសន្លឹកថ្នាំក្ចុតាប ១៤៦
២៦-១-១៩៩៥ -ប្រកាសលេខ ៦២ ផក.ប្រក អនុញ្ញាតអោយលោក ទូច វ៉ា ជនជាតិខ្មែរ បើកដំណើរការរោងជាងជួសជុលរថយន្ត ១៤៧

២៦-១-១៩៩៥ -ប្រកាសលេខ ៦៣ ផក.ប្រក អនុញ្ញាតអោយលោក ឡាត ឆង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៤៧

២៦-១-១៩៩៥ -ប្រកាសលេខ ៦៤ ផក.ប្រក អនុញ្ញាតអោយលោក ងួ ឆាង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៤៧

២៦-១-១៩៩៥ -ប្រកាសលេខ ៦៥ ផក.ប្រក អនុញ្ញាតអោយលោក ចៅ សារឿន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១៤៨

២៦-១-១៩៩៥ -ប្រកាសលេខ ៦៦ ផក.ប្រក អនុញ្ញាតអោយលោក គីម ងួន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១៤៨

២៦-១-១៩៩៥ -ប្រកាសលេខ ៦៧ ផក.ប្រក អនុញ្ញាតអោយលោក ឆាយ ស្រ៊ុង
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៤៩

២៦-១-១៩៩៥ -ប្រកាសលេខ ៦៨ ផក.ប្រក អនុញ្ញាតអោយលោក គួ សួន
ជនជាតិខ្មែរ បើកដំណើររការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ .សេះ ១៤៩

២៦-១-១៩៩៥ -ប្រកាសលេខ ៦៩ ផក.ប្រក អនុញ្ញាតអោយលោក លី សុកហេង
ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកក អនាម័យ ១៥០

២៨-១-១៩៩៥ -ប្រកាសលេខ ៧០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី សេង ឡេង
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣០ សេះ ១៥០

២៩-១-១៩៩៥ -ប្រកាសលេខ ៧១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឡាយ ង៉ែត
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១៥១

២៩-១-១៩៩៥ -ប្រកាសលេខ ៧២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ហ៊ួន វណ្ណនី
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១៥១

២៩-១-១៩៩៤ -ប្រកាសលេខ ៧៣ ផក.ប្រក អនុញ្ញាតអោយលោក ហៅ ឡៃ
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវតអង្ករ យីហោ " ជ័យ ជំនះ "
ម៉ាស៊ីនកំលាំង ២០ សេះ ១៥២

២៩-១-១៩៩៥ -ប្រកាសលេខ ៧៤ ផក.ប្រក អនុញ្ញាតអោយលោក គីម ហាវ
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៥២

២៨-១-១៩៩៥ -ប្រកាសលេខ ៧៥ ផក.ប្រក អនុញ្ញាតអោយលោក ឡេ ប៉ៅសាន់
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២ សេះ ១៥៣

២៨-១-១៩៩៥ -ប្រកាសលេខ ៧៦ ផក.ប្រក អនុញ្ញាតអោយលោក តាន់ ចេង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៥៤

២៨-១-១៩៩៥ -ប្រកាសលេខ ៧៧ ផក.ប្រក អនុញ្ញាតអោយលោក កែវ សួរ
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥.៥ សេះ ១៥៤

២៨-១-១៩៩៥ -ប្រកាសលេខ ៧៨ ផក.ប្រក អនុញ្ញាតអោយលោក ហ៊ុន ណាង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៦ សេះ ១៥៥

២៨-១-១៩៩៥ -ប្រកាសលេខ ៧៩ ផក.ប្រក អនុញ្ញាតអោយលោក សាន់ ម៉ុក
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ ១៥៥

២៨-១-១៩៩៥ -ប្រកាសលេខ ៨០ ផក.ប្រក អនុញ្ញាតអោយលោក តិប ណន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១៥៦

២៨-១-១៩៩៥ -ប្រកាសលេខ ៨១ ផក.ប្រក អនុញ្ញាតអោយលោក នង ប៉េង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៥ សេះ ១៥៦

២៨-១-១៩៩៥ -ប្រកាសលេខ ៨២ ផក.ប្រក អនុញ្ញាតអោយលោក ប៉ែម អៀន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១៥៧

២៨-១-១៩៩៥ -ប្រកាសលេខ ៨៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឈុន សុខលី
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១៥៧

២៨-១-១៩៩៥ -ប្រកាសលេខ ៨៤ ផក.ប្រក អនុញ្ញាតអោយលោក ជឹង វិចិត្រ
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ ១៥៨

២៨-១-១៩៩៥ -ប្រកាសលេខ ៨៥ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុន សុខា
ជនជាតិខ្មែរ បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៥៨

២៨-១-១៩៩៥ -ប្រកាសលេខ ៨៦ ផក.ប្រក អនុញ្ញាតអោយលោក អ៊ី សុធន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៥៩

២៨-១-១៩៥៥ -ប្រកាសលេខ ៨៧ ផក.ប្រក អនុញ្ញាតអោយលោក ផេង ផៃឡេង
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៥៩

២៨-១-១៩៥៥ -ប្រកាសលេខ ៨៨ ផក.ប្រក អនុញ្ញាតអោយលោក លី ច ឈាង
ជនជាតិខ្មែរ បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៥៩

២៨-១-១៩៥៥ -ប្រកាសលេខ ៨៩ ផក.ប្រក អនុញ្ញាតអោយលោក សួន សារឿន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៦០

២៨-១-១៩៥៥ -ប្រកាសលេខ ៩០ ផក.ប្រក អនុញ្ញាតអោយលោក ម៉ៅ តា
ជនជាតិខ្មែរ បើកដំណើរការឡផលិតផ្ទ ក្បឿង ១៦០

២៨-១-១៩៥៥ -ប្រកាសលេខ ៩១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ទេស គំសាន
ជនជាតិខ្មែរ បើកដំណើរការឡ ផលិតផ្ទ ក្បឿងក្បាច់ ១៦១

២៨-១-១៩៥៥ -ប្រកាសលេខ ៩២ ផក.ប្រក អនុញ្ញាតអោយលោក ណី ផាន
ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មឡផ្ទ ក្បឿង ១៦១

២៨-១-១៩៥៥ -ប្រកាសលេខ ៩៥ ផក.ប្រក អនុញ្ញាតអោយលោក តាម ប៊ុន
ជនជាតិខ្មែរ បើកដំណើរការឡចំហុយសន្លឹកថ្នាំកូតាប ១៦១

២៨-១-១៩៥៥ -ប្រកាសលេខ ៩៦ ផក.ប្រក អនុញ្ញាតអោយលោក លឹម សំបូរ
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១៦២

២៨-១-១៩៥៥ -ប្រកាសលេខ ៩៧ ផក.ប្រក អនុញ្ញាតអោយលោក អ៊ិន ឌុច
ជនជាតិខ្មែរ បើកដំណើររោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១៦២

២៨-១-១៩៥៥ -ប្រកាសលេខ ៩៨ ផក.ប្រក អនុញ្ញាតអោយលោក ម៉ុក សាវ៉ាត
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១៦៣

២៨-១-១៩៥៥ -ប្រកាសលេខ ៩៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឡុង ហៀក
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ ១៦៣

២៨-១-១៩៥៥ -ប្រកាសលេខ ១០០ ផក.ប្រក អនុញ្ញាតអោយលោក ឌុច ផល្លា
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១៦៣

២៨-១-១៩៩៥ -ប្រកាសលេខ ១០១ ផក.ប្រក អនុញ្ញាតអោយលោក ឌុច ឌីណា
ជនជាតិខ្មែរ បើកដំណើររោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ១៦៤

២៨-១-១៩៩៥ -ប្រកាសលេខ ១០២ ផក.ប្រក អនុញ្ញាតអោយលោក ប៊ុង ឆៃរី
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ១៦៤

២៨-១-១៩៩៥ -ប្រកាសលេខ ១០៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ហាត់ ម៉ៅ
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៧ សេះ ១៦៥

២៨-១-១៩៩៥ -ប្រកាសលេខ ១០៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ភួន សុភឿន
ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១៦៥

២៨-១-១៩៩៥ -ប្រកាសលេខ ១០៥ ផក.ប្រក អនុញ្ញាតអោយលោក សុខ ហ៊ួរ
ជនជាតិខ្មែរ ជាប្រធានមូលដ្ឋានផលិតកម្មខាត្រស ប្តូរទីតាំងរបស់ខ្លួនទៅតាំង
នៅឃុំថ្មគ្រែ ស្រុកក្រចេះ ខេត្តក្រចេះ ១៦៦

២៨-១-១៩៩៥ -ប្រកាសលេខ ១០៦ ផក.ប្រក អនុញ្ញាតអោយលោក សុក ហេង
ជនជាតិខ្មែរ បើកដំណើរការរោងជាងជួសជុលអំភ្លី និង ម៉ាញ៉ េ.................. ១៦៦

២៨-១-១៩៩៥ -ប្រកាសលេខ ១០៧ ផក.ប្រក អនុញ្ញាតអោយលោក ចាន់ តូ
ជនជាតិខ្មែរ បើកដំណើរការឡផលិតនំប៉័ង ១៦៧

២៨-១-១៩៩៥ -ប្រកាសលេខ ១០៨ ផក.ប្រក អនុញ្ញាតអោយលោក សុខ គី
ជនជាតិខ្មែរ បើកដំណើរការរោងជាងផលិតទ្វារ-បង្អួចដែក ១៦៧

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

៣១-១-១៩៩៥ -ប្រកាសលេខ ២៥ ប្រក.វវស ស្តីពីការបង្កើតគណៈកម្មការដឹកនាំក្រុមការងារ
ស្រាវជ្រាវ តំបន់អភិវឌ្ឍន៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១៦៨

៣-និស្តិការ រដ្ឋមន្ត្រីក្រសួងពតិមាន

ប្រកាស

២៥-១-១៩៩៥ -ប្រកាសលេខ ០១៦-៩៥ ពម.ប្រក ស្តីពីការបង្កើតគណៈកម្មការទទួលអំណោយ ១៦៩

២៨-១-១៩៩៥ -ប្រកាសលេខ ០១៧/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រី រាជការ ១៧១

២៨-១-១៩៩៥ -ប្រកាសលេខ ០១៨/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រី រាជការនៅ
មន្ទីរពតិមានខេត្តកំពត ១៧២

៤-និស្តិការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

២៦-១-១៩៩៥ -ប្រកាសលេខ ០២ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ក្រុងកែប ១៧៣

២៦-១-១៩៩៥ -ប្រកាសលេខ ០៣ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តកំពត ១៧៤

២៨-១-១៩៩៥ -ប្រកាសលេខ ០៤ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត កណ្តាល ១៧៥

២៨-១-១៩៩៥ -ប្រកាសលេខ ០៥ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត សៀមរាប ឧត្តរមានជ័យ ... ១៧៦

២៨-១-១៩៩៥ -ប្រកាសលេខ ០៦ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត កោះកុង ១៧៧

២៨-១-១៩៩៥ -ប្រកាសលេខ ០៧ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត ព្រះវិហារ ១៧៨

២៨-១-១៩៩៥ -ប្រកាសលេខ ០៨ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត បាត់ដំបង ១៧៩

២៨-១-១៩៩៥ -ប្រកាសលេខ ០៩ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត ពោធិសាត់ ១៧៩
២៨-១-១៩៩៥ -ប្រកាសលេខ ១០ កទច ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ
មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្ត កំពង់ធំ ១៨០

៥.ឯកសារក្រសួងសាធារណការ និងដឹកជញ្ជូន

សេចក្តីសំរេច

២៧-១-១៩៩៥ -សេចក្តីសំរេចលេខ ០០៥ ស.រស.ក.ដ.ជ ស្តីពីការកែសំរួលសមាសភាព
គណៈកម្មការចំរុះ អន្តរក្រសួងត្រួតពិនិត្យឆ្នាក់ លើមធ្យោបាយធ្វើដំណើរ
រគ្រប់ប្រភេទ ១៨២

៦.ឯកសារក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២៤-១-១៩៩៥ -ប្រកាសលេខ ០០៨ បទ.ប្រក ស្តីពីការតែងតាំងបជិត្ថាហក:មន្ទីរប្រៃសណីយ៍
និងទូរគមនាគមន៍ ខេត្ត កណ្តាល ១៨៤
៣០-១-១៩៩៥ -ប្រកាសលេខ ០០៩ បទ.ប្រក អនុញ្ញាតអោយអ្នកស្រី វង្ស ថានី បន្តការ
ប្រើប្រាស់ប្រព័ន្ធវិទ្យុទាក់ទងប្រភេទ VHF ១៨៥
៣០-១-១៩៩៥ -ប្រកាសលេខ ០១០ បទប្រក អនុញ្ញាតអោយអ្នកស្រី វង្ស ថានី ផ្អាកឈប់ប្រើ
ប្រព័ន្ធវិទ្យុទាក់ ទងប្រភេទ VHF ចំនួន ០៤ គ្រឿង ១៨៦
៣១-១-១៩៩៥ -ប្រកាសលេខ ០១១ បទ.ប្រក អនុញ្ញាតអោយលោក សៀង អ៊ី ផ្លាស់ប្តូរទី
តាំងបរិក្ខារវិទ្យុ ០១ គ្រឿង ១៨៧

៧.ឯកសារក្រសួងធម្មការ និង សាសនា

ប្រកាស

២៤-១-១៩៩៥ -ប្រកាសលេខ ២១/៩៥ កធស.បុគ្គ ស្តីពីការតែងតាំងមន្ត្រី រាជការ ១៨៩

២៧-១-១៩៩៥ -ប្រកាសលេខ ២៥/៩៥ កធស ស្តីពីការលុបចោលជាស្ថាពរនូវសេចក្តីសំរេច លេខ ២១/៩៥ កធស ចុះថ្ងៃទី ២៤-១-១៩៩៥ ស្តីពីការតែងតាំងមន្ត្រី រាជការ ១៩១

៧-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

២៧-១-១៩៩៥ -ប្រកាសលេខ ០៧៥ ប្រក មស បល ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រី រាជការ ១៩១

២៧-១-១៩៩៥ -ប្រកាសលេខ ០៧៦ ប្រក មស បល ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រី រាជការ ១៩២

៣១-១-១៩៩៥ -ប្រកាសលេខ ០៨៨ ប្រក មស បល ស្តីពីការអនុញ្ញាតអោយផ្អាកការងារដោយ គ្មានបៀវត្ស ១៩៣

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/០៧

ស្តីអំពីការបង្កើតខេត្ត ឧត្តរមានជ័យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរ័ត្ន និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ឈ្វេងយល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឈ្វេងយល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឈ្វេងយល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ព្រះរាជបញ្ញត្តិ

មាត្រា ១ : ត្រូវបានបង្កើតខេត្តឧត្តរ មានជ័យ ។ អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងខេត្តនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ២ : ខេត្តឧត្តរមានជ័យរួមមាន ៤ ស្រុក គឺ : ស្រុកសំរោង ស្រុកចុងកាល់ ស្រុកអន្លង់វែង និង ស្រុកបន្ទាយអំពិល ។

មាត្រា ៣ : យកស្រុកសំរោង ស្រុកចុងកាល់ និង ស្រុកអន្លង់វែង ត្រូវបានកាត់យកពីភូមិសាស្ត្រខេត្តសៀមរាប-ឧត្តរមានជ័យ ។

ត្រូវបានផ្តាច់យកស្រុកបន្ទាយអំពិល ពីភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

មាត្រា ៤ : ស្រុកសំរោងមាន ៤ ឃុំគឺ : ឃុំសំរោង ឃុំកូនក្រៀល ឃុំបុស្បូវ និង ឃុំបន្សាយរាក់ ។

- ស្រុកចុងកាល់មាន ៤ ឃុំគឺ : ឃុំចុងកាល់ ឃុំក្រសាំង ឃុំពង្រ និង ឃុំជើងទៀន ។
- ស្រុកអន្លង់វែងមាន ៥ ឃុំគឺ : ឃុំអន្លង់វែង ឃុំឫស្សី ឃុំត្រពាំងតាវ ឃុំថ្លាវ និង ឃុំរំចេក ។
- ស្រុកបន្ទាយអំពិលមាន ៤ ឃុំគឺ : ឃុំអំពិល ឃុំគោកខ្ពស់ ឃុំគោកមន និង ឃុំបេង ។

មាត្រា ៥ : ទីតាំងសាលាខេត្តឧត្តរមានជ័យ ស្ថិតនៅឃុំសំរោង ស្រុកសំរោង ។

មាត្រា ៦ : ខេត្តសៀមរាប-ឧត្តរមានជ័យបច្ចុប្បន្ន ត្រូវប្តូរឈ្មោះមកជាខេត្តសៀមរាបវិញ ។

មាត្រា ៧ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

មាត្រា ៨ : នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៩ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និង ជំរាប

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

ស ខេង

ហត្ថលេខា និង ត្រា

យូ ហុកគ្រី

ទទួលព្រះរាជបញ្ជាព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២

ហ៊ុន សែន

II- ធិស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១០ អនក្រ
ស្ដីពីការបង្កើត ខុទ្ទកាល័យ ស៊ីវិល ខុទ្ទកាល័យ
យោធានិងនាយកដ្ឋាន ចំណុះក្រសួងការពារជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

-យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតនូវស្ថាប័នដូចខាងក្រោម ដែលស្ថិតនៅក្រោមការគ្រប់គ្រងបញ្ជាផ្ទាល់របស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ គឺ :

.ខុទ្ទកាល័យ ស៊ីវិល

.ខុទ្ទកាល័យ យោធា

.នាយកដ្ឋាន សោធននិវត្តន៍

.នាយកដ្ឋានផ្គត់ផ្គង់

.នាយកដ្ឋាន វិស្វកម្ម

.នាយកដ្ឋានប្រេងឥន្ធនៈ

.នាយកដ្ឋានបញ្ជូនសារ

.នាយកដ្ឋានសុខាភិបាល

.នាយកដ្ឋាន បសុពេទ្យ

មាត្រា ២ : ស្ថាប័នដែលចែងខាងលើនេះ កើតឡើងដោយការកែសំរួលរចនាសម្ព័ន្ធ ខុទ្ទកាល័យ នាយកដ្ឋានកិច្ចការយោធាស៊ីវិល និងនាយកដ្ឋាន ភស្តុភារ របស់ក្រសួង ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធ ពលខេមរភូមិន្ទ និងក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រចនាសម្ព័ន្ធក្រសួងការពារជាតិ



រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១ អនក្រ
ស្តីពីការប្តូរទីរួមខេត្តជាស្រុកនិងសង្កាត់ ឃុំ ក្នុងខេត្តកំពង់ចាម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តកំពង់ចាម មកជាស្រុកកំពង់ចាម ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិទី ៨ ឃុំកំពង់ចាម ។

មាត្រា ២ : ត្រូវបានប្តូរសង្កាត់ចំនួន ៤ ចំណុះទីរួមខេត្ត មកជាឃុំចំនួន ៤ ចំណុះស្រុកកំពង់ចាមគឺ :

សង្កាត់ កំពង់ចាម មកជា ឃុំ កំពង់ចាម

សង្កាត់ វាលវង់ មកជា ឃុំ វាលវង់

សង្កាត់ សំបួរមាស មកជា ឃុំ សំបួរមាស

សង្កាត់ បឹងកុក មកជា ឃុំ បឹងកុក

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពបតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២ អនក្រ
ស្តីពីការប្តូរឈ្មោះស្រុក ទីរួមខេត្ត
សង្កាត់ ក្នុងខេត្ត រតនគិរី

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះស្រុក បានលុង មកជាស្រុក អូរជុំ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តរតនគិរី មកជាស្រុក បានលុង ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិទី ៣ ឃុំ ឡាបានសៀក ។

មាត្រា ៣ : ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនបីចំណុះទីរួមខេត្តមកជាឃុំចំនួនបីចំណុះស្រុក បានលុងគឺ :

- សង្កាត់ យក្សឡោម មកជា ឃុំ យក្សឡោម
- សង្កាត់ ឡាបានសៀក មកជា ឃុំ ឡាបានសៀក
- សង្កាត់ កោះស្វាយ មកជា ឃុំ កាចាញ ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិកការដ្ឋាន និងអភិបាលខេត្ត រតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង១ខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៣ អនក្រ
ស្ដីពីការប្ដូរឋានៈរូបខេត្តជាស្រុក និង ឈ្មោះសង្កាត់
ក្នុងខេត្តស្ទឹងត្រែង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្ដូរទីរួមខេត្តរបស់ខេត្តស្ទឹងត្រែង មកជាស្រុកស្ទឹងត្រែង ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិ កណ្ដាល ឃុំស្ទឹងត្រែង ។

មាត្រា ២ : ត្រូវបានប្ដូរឈ្មោះសង្កាត់ចំនួន ០៤ ចំណុះទីរួមខេត្ត មកជាឃុំចំនួន ០៤ ចំណុះស្រុកស្ទឹងត្រែងគឺ ÷

សង្កាត់ ១ មកជា ឃុំ ស្ទឹងត្រែង

សង្កាត់ ២ មកជា ឃុំ ស្រះឫស្សី

សង្កាត់ ៣ មកជា ឃុំ ព្រះបាទ

សង្កាត់សាមគ្គី មកជា ឃុំ សាមគ្គី

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៤ អនក្រ
ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់ ក្នុងខេត្តកំពត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្ត កំពត មកជាស្រុក កំពង់បាយ ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិ កំពង់បាយខាងជើង ឃុំ កំពង់បាយ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះ សង្កាត់ចំនួនប្រាំ ចំណុះទីរួមខេត្ត មកជាឃុំចំនួនប្រាំ ចំណុះស្រុកកំពង់បាយ គឺ :

សង្កាត់ ១ មកជា ឃុំ កំពង់កណ្តាល

សង្កាត់ ២ មកជា ឃុំ ត្រាំងអំពិល

សង្កាត់ ៣ មកជា ឃុំ កំពង់បាយ

សង្កាត់ ៤ មកជា ឃុំ អណ្តូងខ្មែរ

សង្កាត់ ៥ មកជា ឃុំ ត្រើយកោះ

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៥ អនក្រ
ស្តីពីការប្តូរឈ្មោះ ធីរួមខេត្ត សង្កាត់
ក្នុងខេត្ត ព្រៃវែង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្ត ព្រៃវែង មកជាស្រុកកំពង់លាវ ដែលមានទីតាំងរដ្ឋបាល សាលាស្រុកនៅភូមិ លេខ ៤ ឃុំ កំពង់លាវ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះ សង្កាត់ ចំនួន ប្រាំបី ចំណុះទីរួមខេត្ត មកជាឃុំចំនួន ប្រាំបី ចំណុះ ស្រុកកំពង់លាវ គឺ :

សង្កាត់ កំពង់លាវ មកជា ឃុំ កំពង់លាវ

សង្កាត់ ជើងទឹក មកជា ឃុំ ជើងទឹក

សង្កាត់ បារាយណ៍ មកជា ឃុំ បារាយណ៍

សង្កាត់ តាកោ មកជា ឃុំ តាកោ

សង្កាត់ ព្រែកខ្លោង មកជា ឃុំ ព្រែកខ្លោង

សង្កាត់ ពោធិរៀង មកជា ឃុំ ពោធិរៀង

សង្កាត់ ព្រែកអន្ទះ មកជា ឃុំ ព្រែកអន្ទះ

សង្កាត់ ព្រែកជ្រៃ មកជា ឃុំ ព្រែកជ្រៃ

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៦ អនក្រ
ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តតាកែវ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្ត តាកែវ មកជា ស្រុកដូនកែវ ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិឡូរី ឃុំរការក្នុង ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះ សង្កាត់ ចំនួន បី ចំណុះទីរួមខេត្តមកជាឃុំចំនួន បី ចំណុះស្រុកដូនកែវ គឺ :

-សង្កាត់ រកាក្រៅ មកជា ឃុំ រកាក្រៅ

-សង្កាត់ រកាក្នុង មកជា ឃុំ រកាក្នុង

-សង្កាត់បារាយណ៍ មកជា ឃុំ បារាយណ៍

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាល ខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៧ អនក្រ
ស្ដីពីការប្ដូរឈ្មោះស្រុក ទីរួមខេត្ត សង្កាត់ក្នុងខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃ ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្ដូរឈ្មោះស្រុក សិរីសោភ័ណ មកជា ស្រុក អូរជ្រៅ ដែលមានទីតាំងរដ្ឋបាលសាលាស្រុក អូរជ្រៅ តាំងនៅភូមិគីឡូលេខ ៤ ឃុំ ប៉ោយប៉ែត ។

មាត្រា ២ : ត្រូវបានប្ដូរឈ្មោះ ទីរួមខេត្តរបស់ខេត្តបន្ទាយមានជ័យ មកជាស្រុកសិរីសោភ័ណ ដែលមានទីតាំងរដ្ឋបាល សាលាស្រុក នៅភូមិ កំពង់ស្វាយ ឃុំ កំពង់ស្វាយ ។

មាត្រា ៣ : ត្រូវបានប្ដូរឈ្មោះ សង្កាត់ចំនួន ប្រាំបី ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួន ប្រាំបី ចំណុះស្រុក សិរីសោភ័ណ គឺ ÷

១-សង្កាត់ ម្កាក់ មកជា ឃុំ ម្កាក់

២-សង្កាត់ ប៉ុស្បូវ មកជា ឃុំ ប៉ុស្បូវ

៣-សង្កាត់ ភ្នៀត មកជា ឃុំ ភ្នៀត

៤-សង្កាត់ ទឹកថ្លា មកជា ឃុំ ទឹកថ្លា

៥-សង្កាត់ អូរអំបិល មកជា ឃុំ អូរអំបិល

៦-សង្កាត់ ព្រះពន្លា មកជា ឃុំ ព្រះពន្លា

៧-សង្កាត់ កំពង់ស្វាយ មកជា ឃុំ កំពង់ស្វាយ

៨_សង្កាត់ កោះពងសត្វ មកជា ឃុំ កោះពងសត្វ ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៨ អនក្រ
ស្តីពីការប្តូរឈ្មោះពីរូមខេត្ត សង្កាត់ ឃុំ ក្នុងខេត្ត កំពង់ឆ្នាំង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្ត កំពង់ឆ្នាំង មកជាស្រុក កំពង់ឆ្នាំង ដែលមានទីតាំងរដ្ឋបាល សាលាស្រុក នៅភូមិស្រែព្រាំង ឃុំ កំពង់ឆ្នាំង ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះសង្កាត់ ចំនួន បួន ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួន បួន ចំណុះស្រុក កំពង់ឆ្នាំងគឺ ÷

សង្កាត់លេខ ១ មកជា ឃុំ ផ្សារឆ្នាំង

សង្កាត់លេខ ២ មកជា ឃុំ កំពង់ឆ្នាំង

សង្កាត់លេខ ៣ មកជា ឃុំ ផ្អេរ

សង្កាត់លេខ ៤ មកជា ឃុំ ខ្សាម ។

មាត្រា ៣ ៖ ត្រូវបានប្តូរឈ្មោះឃុំកំពង់ឆ្នាំង ក្នុងស្រុក ជលគិរី មកជា ឃុំ កំពង់អុសក្នុងស្រុកជលគិរី ។

មាត្រា ៤ ៖ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៦ ៖ អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៥ អនក្រ
ស្តីពីការប្តូរឈ្មោះឃុំមខេត្ត សង្កាត់
ក្នុងខេត្ត មណ្ឌលគិរី

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តមណ្ឌលគិរី មកជា ស្រុក សែនមនោរម្យ ដែលមាន ទីតាំងរដ្ឋបាលសាលា ស្រុក នៅភូមិចំបក់ ឃុំ ស្ពានមានជ័យ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន បួន ចំណុះទីរួមខេត្តមកជា ឃុំចំនួន បួន ចំណុះស្រុកសែនមនោរម្យ គឺ :

-សង្កាត់ទី ១ មកជា ឃុំ មនោរម្យ

-សង្កាត់ទី ២ មកជា ឃុំ សុខដុម

-សង្កាត់ទី ៣ មកជា ឃុំ ស្ពានមានជ័យ

-សង្កាត់ទី ៤ មកជា ឃុំ រមនា

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២០ អនក្រ
ស្តីពីការប្តូរឈ្មោះទីរួមខេត្ត
សង្កាត់ ក្នុងខេត្តព្រះវិហារ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះ ទីរួមខេត្ត របស់ខេត្ត ព្រះវិហារ មកជាស្រុកត្បែងមានជ័យ ដែលមានទីតាំងរដ្ឋបាល សាលាស្រុក នៅភូមិការកិច្ច ឃុំ ប៉ាលហាល ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះ សង្កាត់ មិត្តភាព ចំណុះទីរួមខេត្ត មកជា ឃុំកំពង់ប្រណាក ចំណុះស្រុកត្បែងមានជ័យ ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២១ អនក្រ
ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់
ក្នុងខេត្តកោះកុង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តកោះកុង មកជាស្រុក ស្មាច់មានជ័យ ដែលមានទីតាំងរដ្ឋបាលសាលា ស្រុកនៅភូមិ ស្ទឹង វែង ឃុំ ស្ទឹងវែង ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន បី ចំណុះទីរួមខេត្ត មកជាឃុំចំនួន បី ចំណុះស្រុកស្មាច់មានជ័យ គឺ :

សង្កាត់ ១ មកជា ឃុំ ស្មាច់មានជ័យ

សង្កាត់ ២ មកជា ឃុំ ដងទង់

សង្កាត់ ៣ មកជា ឃុំ ស្ទឹងវែង

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២២ អនក្រ
ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់
ក្នុងខេត្តពោធិសាត់

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះ ទីរួមខេត្ត របស់ខេត្តពោធិសាត់ មកជាស្រុក សំពៅមាស ដែលមានទីតាំងរដ្ឋបាល សាលាស្រុកនៅភូមិ ពាលញែក ១ ឃុំ ផ្ទះព្រៃ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះសង្កាត់ ចំនួន ប្រាំពីរ ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួនប្រាំពីរ ចំណុះស្រុក សំពៅមាស ។

-សង្កាត់ រលាប មកជា ឃុំ រលាប

-សង្កាត់ ផ្ទះព្រៃ មកជា ឃុំ ផ្ទះព្រៃ

-សង្កាត់ កោះជុំ មកជា ឃុំ កោះជុំ

-សង្កាត់ លលកសរ មកជា ឃុំ លលកសរ

-សង្កាត់ ព្រៃញី មកជា ឃុំ ព្រៃញី

-សង្កាត់ ស្វាយអាត់ មកជា ឃុំ ស្វាយអាត់

-សង្កាត់ ចំរើនផល មកជា ឃុំ ចំរើនផល

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៣ អនក្រ
ស្ដីពីការប្ដូរឈ្មោះទីរួមខេត្ត សង្កាត់
ក្នុងខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្ដូរឈ្មោះទីរួមខេត្តរបស់ខេត្តកំពង់ស្ពឺ មកជាស្រុកច្បារមន ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិត្រស់ ឃុំសេរីភាព ។

មាត្រា ២ : ត្រូវបានប្ដូរឈ្មោះសង្កាត់ចំនួនប្រាំ ចំណុះទីរួមខេត្ត មកជាឃុំចំនួនប្រាំ ចំណុះស្រុកច្បារមនគឺ÷

-សង្កាត់ ច្បារមន មកជា ឃុំ ច្បារមន

-សង្កាត់ ឯករាជ មកជា ឃុំ កណ្ដោលដុំ

-សង្កាត់ សន្តិភាព មកជា ឃុំ រការធំ

-សង្កាត់ សេរីភាព មកជា ឃុំ ស្វាយក្រវ៉ាន់

-សង្កាត់ សុព័រទេព មកជា ឃុំ សុព័រទេព

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៤ : អនុក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៤ អនក្រ
ស្ដីពីការប្ដូរឈ្មោះ ស្រុកឈរ៉ូមខេត្ត
និង សង្កាត់ក្នុងខេត្ត សៀមរាប

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្ដូរឈ្មោះស្រុក សៀមរាប មកជា ស្រុក ប្រាសាទបាគង ។

មាត្រា ២ : ត្រូវបានប្ដូរឈរ៉ូមខេត្ត របស់ខេត្តសៀមរាប មកជា ស្រុក សៀមរាប ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិ បន្ទាយចាស់ ឃុំ ស្លក្រាម ។

មាត្រា ៣ : ត្រូវបានប្ដូរឈ្មោះសង្កាត់ ចំនួន ១០ ចំណុះឈរ៉ូមខេត្ត មកជា ឃុំ ចំនួន ១០ ចំណុះស្រុក សៀមរាប គឺ ៖

- សង្កាត់ ១ មកជា ឃុំ ស្លក្រាម
- សង្កាត់ ២ មកជា ឃុំ ស្វាយដង្គុំ
- សង្កាត់ ៣ មកជា ឃុំ គោកចក
- សង្កាត់ ៤ មកជា ឃុំ សាលាកំរើក

-សង្កាត់ ជ្រាវ មកជា ឃុំ ជ្រាវ

-សង្កាត់ សៀមរាប មកជា ឃុំ សៀមរាប

-សង្កាត់ នគរធំ មកជា ឃុំ នគរធំ

-សង្កាត់ សំបួរ មកជា ឃុំ សំបួរ

-សង្កាត់ ស្រងែ មកជា ឃុំ ស្រងែ

-សង្កាត់ ចុងឃ្នៀស មកជា ឃុំ ចុងឃ្នៀស

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត សៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៥ អនក្រ
ស្តីពីការប្តូរឈ្មោះពីរូមខេត្ត
សង្កាត់ក្នុងខេត្តបាត់ដំបង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តបាត់ដំបង មកជាស្រុកស្វាយប៉ោ ដែលមានទីតាំងរដ្ឋបាលសាលា ស្រុក នៅភូមិ កំពង់ក្របី ឃុំស្វាយប៉ោ ។

មាត្រា ២ : ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនដប់ ចំណុះទីរួមខេត្ត មកជាឃុំ ចំនួនដប់ ចំណុះស្រុកស្វាយប៉ោ គឺ ÷

-សង្កាត់ ចំការសំរោង មកជា ឃុំ ចំការសំរោង

-សង្កាត់ ឯកភាព មកជា ឃុំ ស្វាយប៉ោ

-សង្កាត់ មិត្តភាព មកជា ឃុំ ស្លាកែត

-សង្កាត់ ស្វាយប៉ោ១ មកជា ឃុំ ទួលតាឯក

-សង្កាត់ ស្វាយប៉ោ២ មកជា ឃុំ ព្រែកព្រះស្តេច

-សង្កាត់ ស្វាយប៉ោ៣ មកជា ឃុំ រតនៈ

-សង្កាត់ សាមគ្គី មកជា ឃុំ អូរចារ

-សង្កាត់ ក្តុលដូនទាវ មកជា ឃុំ ក្តុលដូនទាវ

-សង្កាត់ អូរម៉ាល់ មកជា ឃុំ អូរម៉ាល់

-សង្កាត់ វត្តគរ មកជា ឃុំ វត្តគរ

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះ មានអានុភាពអតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៦ អនក្រ
ស្ដីពីការប្ដូរឈ្មោះទីរួមខេត្ត
សង្កាត់ ក្នុងខេត្តកំពង់ធំ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្ដូរឈ្មោះទីរួមខេត្តរបស់ខេត្ត កំពង់ធំ មកជាស្រុក ស្ទឹងសែន ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិ កំពង់ធំ ឃុំ កំពង់រទេះ ។

មាត្រា ២ : ត្រូវបានប្ដូរឈ្មោះ សង្កាត់ចំនួនប្រាំបួន ចំណុះទីរួមខេត្តមកជាឃុំចំនួនប្រាំបួន ចំណុះស្រុកស្ទឹងសែន ។

សង្កាត់ ១ មកជា ឃុំ ដំរីជាន់ខ្លា
សង្កាត់ ២ មកជា ឃុំ កំពង់ធំ
សង្កាត់ ៣ មកជា ឃុំ កំពង់រទេះ
សង្កាត់ ៤ មកជា ឃុំ អូរកន្ធរ
សង្កាត់ ៥ មកជា ឃុំ ក្ដីដូង
សង្កាត់ ៦ មកជា ឃុំ កំពង់ក្របៅ
សង្កាត់ ៧ មកជា ឃុំ ព្រៃគុយ
សង្កាត់ ៨ មកជា ឃុំ ព្រៃតាហ៊ូ
សង្កាត់ ៩ មកជា ឃុំ អាចារ្យលាក់

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ : អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ២៧ អនក្រ
ស្តីពីការប្តូរឈ្មោះស្រុក ទីរួមខេត្ត
សង្កាត់ក្នុងខេត្តស្វាយរៀង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
ប្រការ ៣ ៖ ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៩៩ ជក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ ៖ អនុញ្ញាតអោយ អ្នកស្រី ឡុង ហៀក ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៥៤២៧ ក.ស្ព ចុះថ្ងៃទី ២២-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ កណ្តាល ឃុំ វល្លិស ស្រុក សំរោងទង ខេត្ត កំពង់ស្ពឺ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ ៖ អ្នកស្រី ឡុង ហៀក ត្រូវបន្តដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ ៖ ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១០០ ជក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ ៖ អនុញ្ញាតអោយលោក ឌុច ផល្លា ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៧២៨៣ ក.ធ ចុះថ្ងៃទី ១២-០២-៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រែកស្បូវ សង្កាត់លេខ ៤ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ ៖ លោក ឌុច ផល្លា ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០១ ឧក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ឌុច ឌីណា ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៤៩៥០ ក.ច ចុះថ្ងៃទី ២២-០១-៨៧ អាសយដ្ឋានបច្ចុប្បន្ន ក្រុមទី ១២ ភូមិ អូរគន្ធរ ខាងត្បូង សង្កាត់លេខ ៤ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ នៅក្នុងទីតាំង ដូចអាសយដ្ឋានខាងលើ ។

ប្រការ ២ : លោក ឌុច ឌីណា ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០២ ឧក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ប៊ុង ឆៃរី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់ អត្តសញ្ញាណប័ណ្ណលេខ ០០៣៨៤៤ ក.ច ចុះថ្ងៃទី ១១-០១-៨៧ អាសយដ្ឋានបច្ចុប្បន្ន ក្រុមទី ៤ ភូមិ ព្រែកស្បូវ សង្កាត់លេខ ៤ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាសយដ្ឋានខាងលើ ។

ប្រការ ២ : លោក ប៊ុង ឆៃរី ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ពី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១០៣ ផក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី ហាត់ ប៉ៅ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៦៧៦៨ ក.ធ ចុះថ្ងៃទី ១៥-១២-៨៦អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ២ ភូមិ ពោធិបាក់ក សង្កាត់លេខ ១ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ បើក ដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៧ សេះ នៅក្នុងទីតាំង ក្រុមទី ២ ភូមិ កំពង់ធំ សង្កាត់លេខ ៣ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ ។

ប្រការ ២ : អ្នកស្រី ហាត់ ប៉ៅ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ពី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៤ ផក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី ភួន សុភឿន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៨៣៥៤ ក.ណ ចុះថ្ងៃទី ៣០-៩-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ក្អង ឃុំ ព្រែកតាកោ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី ភួន សុភឿន ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៥ ធក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក សុខ ហ៊ួរ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៤៣០៦៧៦ ក.៦ ចុះថ្ងៃទី ២១-០២-៩២ ជាប្រធានមូលដ្ឋាន ផលិតកម្ម ខាត្រូស ដែលមានទីតាំងនៅ ភូមិ ព្រែកបាក់ ឃុំ ព្រែកបាក់ ស្រុក ស្ទឹងត្រង់ ខេត្ត កំពង់ចាម ប្តូរទីតាំងរបស់ខ្លួនទៅកាន់មូលដ្ឋានថ្មី ។

ប្រការ ២ : ទទួលស្គាល់ទីតាំងផលិតកម្ម ខាត្រូសថ្មី របស់លោក សុខ ហ៊ួរ ដែលតាំងនៅឃុំ ថ្មីគ្រែ ស្រុក ក្រចេះ ខេត្ត ក្រចេះ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៤ : ប្រកាសលេខ ៣៤ ធក.ប្រក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍

* * *

ប្រកាសលេខ ១០៦ ធក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក សុក ហេង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៦៦៤៨៤ ភ.៣ ចុះថ្ងៃទី ២២-៦-៩២ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៩០ ក្រុមទី ៤ ភូមិ មិត្តភាព ឃុំ ឬស្សីកែវ ស្រុក ឬស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការ រោងជាង ផ្លាស់ប្តូរអំពូល និង ម៉ាញ៉េ នៅក្នុងទីតាំង ផ្ទះលេខ ១៤០ អឺ០ ផ្លូវលេខ ១០៧ ក្រុមទី ២២ សង្កាត់ អូរឫស្សីទី ៤ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ១០៧ ផក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ចាន់ តួ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៤៣៧ ក.ធ ចុះថ្ងៃទី ២៩-៧-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ដីជាន់ខ្លា សង្កាត់លេខ ១ ទីរួមខេត្ត កំពង់ធំ ខេត្ត កំពង់ធំ បើកដំណើរការ ឡផលិតនំបុ័ង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៨ ផក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក សុខ គី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៥៥៥៨ ក.រ ចុះថ្ងៃទី ២០-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២៨១ ផ្លូវជាតិលេខ ២ ក្រុមទី ១៦ ភូមិ ព្រែកតាគង់ សង្កាត់ ចាក់អង្រែ ស្រុក មានជ័យ រាជធានីភ្នំពេញ បើកដំណើរការ រោងជាងផលិតទ្វារ-បង្អួចដែក នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៩

ប្រកាសលេខ ២៥ ប្រក.វវស
ស្តីពីការបង្កើតគណៈកម្មការដឹកនាំក្រុម
ការងារចុះស្រាវជ្រាវ តំបន់អភិវឌ្ឍន៍

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីត្រូវការចាំបាច់របស់ក្រសួង

មាត្រា ១ : បង្កើតគណៈកម្មការមួយដើម្បីដឹកនាំក្រុមការងារចុះស្រាវជ្រាវ តំបន់អភិវឌ្ឍន៍

មាត្រា ២ : សមាសភាពនៃគណៈកម្មការនេះរួមមាន :

១. លោកស្រី **កាន់ ផុន** ជំនួយការឯកឧត្តមរដ្ឋមន្ត្រី	ប្រធាន
២. លោក **អ៊ុក ជា** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី	អនុប្រធាន
៣. លោក **ពេជ្រ ចំរុងពិល** អគ្គនាយកបច្ចេកទេស	សមាជិក
៤. លោក **ជុច ភឿន** ប្រធាននាយកដ្ឋានបេតិកភណ្ឌ	សមាជិ
៥. លោក **អ៊ុំ មង្គល** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី	សមាជិក
៦. លោក **ជីង ឈង** អនុប្រធាននាយកដ្ឋានផែនការ	សមាជិក
៧. លោក **អ៊ុក សុជាតិ** អនុប្រធាននាយកដ្ឋានបុគ្គលិក	សមាជិក
៨. លោក **ហោ ឡុក** ប្រធានការិ. សំណង់ នា.ផែនការ	សមាជិក.
៩. លោក **អ៊ិន ស៊ីយ៉ុណ្ណា** ទទួលខុសត្រូវនាយកដ្ឋានសិល្បៈសូនរូប និង សិប្បកម្ម	សមាជិក

មាត្រា ៣ : គណៈកម្មការនេះមានភារកិច្ច :

-គ្រប់គ្រងសមាជិកក្រុម បែងចែកតាមតំបន់នីមួយៗ

-សម្របសម្រួលការងារដែលទាក់ទងនឹងការស្រាវជ្រាវ

-ណែនាំអំពីកម្មវិធីបច្ចេកទេស

-ផ្តល់យោបល់ និង ពត៌មាន អំពីសកម្មភាព និង លទ្ធផលនៃការស្រាវជ្រាវរបស់ក្រុមនីមួយៗ

មាត្រា ៤ : ខុទ្ទកាល័យ-អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានបច្ចេកទេស-នាយកដ្ឋានបុគ្គលិក-សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ចប់ការងារស្រាវជ្រាវនេះ ជាស្ថាពរ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ុង

***

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន
ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១៦.៩៥ ពម.ប្រក
ស្តីពីការ បង្កើតគណៈកម្មការទទួលអំណោយ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-ពិនិត្យលើតម្រូវការ និង សំណូមពរចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការរបស់ក្រសួងមួយដើម្បីទទួល សំភារៈបរិក្ខាវិទ្យុ ជាអំណោយរបស់ប្រទេសបារាំង ដល់ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ :

១_ឯកឧត្តម **អ៊ុំ ធាសិាម** អនុរដ្ឋលេខាធិការ	ប្រធាន
២_លោក **ម៉ាន់ សេខលី** អគ្គនាយកវិទ្យុជាតិកម្ពុជា	អនុប្រធាន
៣_លោក **សេខ ម៉ាលីស** អគ្គនាយករងរដ្ឋបាល ហិរញ្ញកិច្ច	សមាជិក
៤_លោក **សាន សំបូរ** អគ្គនាយករងរដ្ឋបាល ហិរញ្ញកិច្ច	សមាជិក
៥_លោក **សែន សំណាខ** អាគ្គាធិការរង	សមាជិក
៦_ **នួម សុខគ្រី** អគ្គនាយករងវិទ្យុជាតិកម្ពុជា	សមាជិក
៧_លោក **គន់ យ៉ាន** អគ្គនាយករងវិទ្យុជាតិកម្ពុជា	សមាជិក

ប្រការ ២ : គណៈកម្មការ នេះមានភារកិច្ចទទួលខុសត្រូវចំពោះទទួលអំណោយ ពីភាគីប្រទេសបារាំង ព្រមទាំងធ្វើបញ្ជីសារពើភ័ណ្ឌ អោយបានត្រឹមត្រូវ និង ធ្វើសេចក្តីរាយការណ៍ជូនក្រសួង ។

ប្រការ ៣ : ទីស្តីការ រដ្ឋមន្ត្រី អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា និង សាមីខ្លួនមានភារកិច្ច អនុវត្ត អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១៧/៩៥ ពម.ប្រក
ស្តីពីការលុបឈ្មោះ មន្ត្រី រាជការ

_យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

_បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យលើលិខិតបញ្ជូនលេខ ១៤៤ ពមខ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់មន្ទីរពត៌មាន ខេត្តបន្ទាយមានជ័យ

-ពិនិត្យលើសភាពការណ៍ជាក់ស្តែង

ប្រការ ១ : លុបឈ្មោះ **សុគ ល្វត** ចេញពីក្របខ័ណ្ឌរបស់មន្ទីរពត៌មាន ខេត្ត បន្ទាយមានជ័យ ចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៥ នេះតទៅ ដោយសាមីខ្លួន ស្ម័គ្រចិត្តសុំឈប់បំរើការងារ ។

ប្រការ ២ : លោក **សុគ ល្វត** ដូចមានចែងក្នុងប្រការ ១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងប្រាក់បៀវត្ស លោក **សុគ ល្វត** : ៣៨.៥៥០៛ គុណ ៦ : ២៣១.៣០០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ,មន្ទីរពត៌មាន ខេត្ត បន្ទាយមានជ័យ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១៨/៩៥ ពម
ស្តីពីការលុបឈ្មោះ មន្ត្រីរាជការ
នៅមន្ទីរពត៌មានខេត្ត កំពត

-យោងព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យសំណើលេខ ០១.៩៥ គន ព.ម.កព ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មានខេត្ត កំពត

-ពិនិត្យសំណើលេខ ០៤.៩៥ គន.ព.ម.កព ចុះថ្ងៃទី ០៧ មករា ១៩៩៥ របស់មន្ទីរពត៌មានខេត្ត កំពត

សម្រេច

ប្រការ ១ : លុបឈ្មោះមន្ត្រីរាជការចំនួន ០២ នាក់ ចេញពីក្របខ័ណ្ឌមន្ទីរពត៌មានខេត្ត កំពត មូលហេតុបោះបង់ចោលការងារ ដូចមានរាយនាមខាងក្រោមនេះ :

១. **ចាន់ សាម៉ន** បុគ្គលិក ការិយាល័យពត៌មាន ស្រុកកំពង់ត្រាច

២. **កែម ចំរើនរិទ្ធិ** បុគ្គលិក ការិយាល័យពត៌មាន ស្រុក កំពត

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីជនទាំងពីរ ត្រូវកាត់ផ្តាច់ពីថ្ងៃទី ខែ មិនា ឆ្នាំ ១៩៩៥ តទៅ

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្ត កំពត និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៤. ឯកសារដែលរដ្ឋមន្ត្រីក្រសួងធនធានសារធារណ៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០២ កធធ

ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះ

មន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរធនធានសារធារណ៍ ក្រុងកែប

រដ្ឋមន្ត្រីក្រសួងធនធានសារធារណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

-យោងប្រកាសលេខ ៨៩៣ កទច ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ១៩៩៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍ក្រុងកែប ។

-យោងលិខិតលេខ ១៤ សំណក្រក ចុះថ្ងៃទី ១៣ ខែ ធ្នូ ១៩៩៤ របស់សាលាក្រុងកែប ។

-យោងតាមសំណូមពរការកិច្ចចាំបាច់នៃការងារអភិវឌ្ឍវិស័យទេសចរណ៍ ។

ប្រការ ១ : តែងតាំង :

១-លោក **ឈេង យុទ្ធី** ជាប្រធានមន្ទីរទេសចរណ៍

២-លោក **ឯល ណារី** ជាអនុប្រធានមន្ទីរទេសចរណ៍

ប្រការ ២ : ចំពោះមន្ត្រីថ្នាក់ការិយាល័យ ក្រសួងនឹងរៀបចំចាត់តាំងជាក្រោយ ។

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ក្រុងកែប ចំនួន ១០ នាក់ ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ក្រុងកែប និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

***

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៣ កទច
ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តកំពត

ប្រការ ១ : តែងតាំង :

១-លោក **រំណាម ស៊ីនួន** ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២-លោក **មិន សុចត្តិ** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក-ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១-លោក **សយ ស៊ីណុល** ជាប្រធាន

២-លោក **លី តា** ជាអនុប្រធានទី ១

៣_លោក ឃឹម សុវណ្ណារ៉ា ជាអនុប្រធានទី ២

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១_លោក សូ ដានី ជាប្រធាន

២_លោក ស្វាយ សារ៉ាត់ ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍វប្បធម៌ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១_លោក សេក ស៊ុន ជាប្រធាន

២_លោកស្រី ជិន សុខិម ជាអនុប្រធាន

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្តកំពតចំនួន ១៥ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តកំពត និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤ កណច
ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការ
និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តកណ្តាល

ប្រការ ១ : តែងតាំង :

១_លោក ថៃ ប៊ុនឈឿន ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_លោក ពៅ សុខន ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក ជុំ ជួន ជាប្រធាន

២_លោក អ៊ុំ គិមសាន ជាអនុប្រធាន

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និងផ្សព្វផ្សាយ

១_លោក អ៊ុក នី ជាប្រធាន

២_លោក ជុំ ចំនួតខ ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍វប្បធម៌ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១_លោក ជៀង រតនៈ ជាប្រធាន

២_លោក សេក សោភ័ណ្ឌ ជាអនុប្រធាន

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្តកណ្តាល ចំនួន ១៤ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល និង សាម៉ីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៥ គណច

ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ត្រីទេសចរណ៍ ខេត្តសៀមរាប-ឧត្តរមានជ័យ

ប្រការ ១ : តែងតាំង :

១_លោក តោ ស៊ុំ សារឿក ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_លោក គុយ សខ ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បួនការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក សោ វិសិដ្ឋ ជាប្រធាន

២_លោកស្រី កាន់ វែងចណ្ណា ជាអនុប្រធានទី ១

៣_លោក ឆឹយ ឆន ជាអនុប្រធានទី ២

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ និងផែនការ

១_លោក ហាច សុគ្គា ជាប្រធាន

២_លោកស្រី ជា មាលតី ជាអនុប្រធានទី ១

៣_លោក ឈូក ចាន់ធុម ជាអនុប្រធានទី ២

គ.ការិយាល័យអភិវឌ្ឍន៍ទេសចរណ៍ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១_លោក សួន ធុរ៉ាន ជាប្រធាន

២_លោក ពិន សុវណ្ណ ជាអនុប្រធានទី ១

៣_លោក ធន់ ចាន់នី ជាអនុប្រធានទី ២

ឃ.ការិយាល័យឃោសនាផ្សព្វផ្សាយ

១_កញ្ញា គួច សូរ៉ុន ជាប្រធាន

២_កញ្ញា កែវ សុភាព ជាអនុប្រធានទី ១

៣_លោក ស៊ុំ សារ៉ាយ ជាអនុប្រធានទី ២

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌ មន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្តសៀមរាប_ឧត្តរមានជ័យ ចំនួន ៦០ កន្លែង

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប_ឧត្តរមានជ័យ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៩

ប្រកាសលេខ ០៦ កឧច

ស្តីពីការកែងតាំងជាបណ្តោះអាសន្នចំពោះមន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ខេត្ត កោះកុង

ប្រការ ១ : តែងតាំង :

១_លោក ប៊ុន ឡៀប ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_លោក ជិន អ៊ីុយ ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក ប៊ូ អេង ជាប្រធាន

២_លោក ម៉ា ឈៀង ជាអនុប្រធានទី ១

៣_លោក យិ យឹម ជាអនុប្រធានទី ២

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១_លោក យឹម សានិក ជាប្រធាន

២_លោកស្រី សុវណ្ណារិទ្ធ ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍ទេសចរណ៍ និង មណ្ឌលទិដ្ឋាជីវ:

១_អ្នកស្រី មាង ម៉ាយូដា ជាប្រធាន

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការ របស់មន្ទីរទេសចរណ៍ខេត្ត កោះកុង ចំនួន ០៨ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង និង សាម៉ីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៧ កេទ
ស្ដីពីការតែងតាំងជាបណ្ដោះអាសន្ន ចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តព្រះវិហារ

ប្រការ ១ : តែងតាំង :

១_លោក ជូ ប៊ុនថៃ ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_អ្នកស្រី ទេព សុខុម ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក **ម៉ែន ចុក្តា** ជាប្រធាន

២_លោក **ព្រហ្ម ខារ៉ា** ជាអនុប្រធានទី ១

៣_លោក **តិក ចំន្ទី** ជាអនុប្រធានទី ២

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១_លោក **គង់ ចិបុល** ជាប្រធាន

២_លោក **ឈុន ហាក់** ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍ចប្បធម៌ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១.**ម៉ែន ម៉ាន់ជូ** ជាប្រធាន

២_លោកស្រី **កេត ណាងអូន** ជាអនុប្រធានទី ១

៣_លោក **សំហ៊ុម** ជាអនុប្រធានទី ២

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្ត ព្រះវិហារចំនួន ១៣ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តព្រះវិហារ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥ .

ប្រកាសលេខ ០៨ កឧប
ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការ
និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តបាត់ដំបង

ប្រការ ១ : តែងតាំង :

១_លោក **ប៉ាន ប៊ុនរឿន** ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_អ្នកស្រី **លី គីមលៀង** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១-លោក ម៉ក់ ស៊ុនណារ៉ា ជាប្រធាន

២-លោក ឆុយ វ៉ុន ជាអនុប្រធាន

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១-លោក អ៊ិន វុទ្ធារ៉ា ជាប្រធាន

២-លោក ម៉ូច ខន ជាអនុប្រធានទី ១

៣-លោក ឡៅ ចារីខេមរា ជាអនុប្រធានទី ២

គ.ការិយាល័យអភិវឌ្ឍន៍បច្ចេកទេស និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១-លោក យុក សុផា ជាប្រធាន

២-លោក ម៉ិល សែ ជាអនុប្រធានទី ១

៣-លោក នាល ហ៊ិន ជាអនុប្រធានទី ២

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌ មន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបងចំនួន ១៨ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៩ គណច

ស្តីពីការតែងតាំងឋានៈអាសន្ន ចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តពោធិ៍សាត់

ប្រការ ១ : តែងតាំង :

១-លោក ញ៉ែម សុខ ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២-លោក កែប សោភ័ណ្ឌ ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក កែវ ឈាង ជាប្រធាន

២_លោក ឆិក សារឹម ជាអនុប្រធានទី ១

៣_លោក សេង ហុង ជាអនុប្រធានទី ២

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១_លោក ជេក សុផល ជាប្រធាន

២_លោក នួច សុចិន ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍ទប្បធមិ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ

១_លោក ខ្វាន់ សារុន ជាប្រធាន

២_លោក ឈឹម ផន ជាអនុប្រធានទី ១

៣_លោក អ៊ុច យ៉ុន ជាអនុប្រធានទី ២

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្ត ពោធិសាត់ចំនួន ១៨ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១០ កឆប
ស្ដីពីការតែងតាំងឋានៈឈ្មោះអាសន្ន ចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ ខេត្តកំពង់ធំ

ប្រការ ១ : តែងតាំង :

១_លោក សំម រឹម ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២_លោក ថៃ ជាវរិទ្ធិ ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក.ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

១_លោក **សរ សារិន** ជាប្រធាន

២_លោក **ម៉ាន់ សាវ៉ាត់** ជាអនុប្រធាន

ខ.ការិយាល័យ ឧស្សាហកម្មទេសចរណ៍ រំដែនការ និង ផ្សព្វផ្សាយ

១_លោក **ប៊ិន គីមលាក** ជាប្រធាន

២_លោក **សារាយ សំខាន់** ជាអនុប្រធាន

គ.ការិយាល័យអភិវឌ្ឍន៍ធម្មជាតិ និង មណ្ឌលបណ្តុះវិជ្ជាជីវៈ

១_លោក **កាន់ ឆាន** ជាប្រធាន

២_លោក **អ៊ុក សាន** ជាអនុប្រធានទី ១

៣_លោក **ហេង គុកញ៉េ** ជាអនុប្រធានទី ២

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍ខេត្ត កំពង់ធំចំនួន ១៣ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត_ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វ៉េង សេរីវុឌ្ឍ

***

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០០៥ ស.រ.ស.ក.ជ.ជ

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញលិខិតលេខ ០១ ស.ជ.ណ.គ.ប ចុះថ្ងៃទី ០៤-០១-១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញលិខិតលេខ ០៩ ប្រក.សក.ជជ ចុះថ្ងៃទី ០៤-០២-១៩៩៤ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

-បានឃើញលិខិតផ្ទេរលេខ ០០៧ ប្រក.សកប ចុះថ្ងៃទី ០៦-០១-៩៥ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

-ពិនិត្យសំណូមពរចាំបាច់ ធ្វើការកែសំរួលសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងត្រួតពិនិត្យ ធ្នត់លើរបៀបធ្វើដំណើរគ្រប់ប្រភេទ ទាំងផ្លូវគោក និងទឹក ។

សំរេច

ប្រការ ១ : សមាសភាព គណៈកម្មការចំរុះអន្តរក្រសួងត្រួតពិនិត្យធ្នត់ លើរបៀបធ្វើដំណើរគ្រប់ប្រភេទ ទាំងផ្លូវគោក និង ផ្លូវទឹក ត្រូវបានកែសំរួលដូចតទៅ:

១-លោក **ជួន ពេជ្រ** មន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២-លោក **ហោ អៀង** ប្រធានផ្នែកជលយាននៃការិយាល័យត្រួតពិនិត្យយានយន្តក្រសួង សាធារណការនិងដឹកជញ្ជូន ជា អនុប្រធានទី ១

៣-លោក វរសេនីយ៍ត្រី **មាស ខុនឌីណា** តំណាងក្រសួងមហាផ្ទៃសន្តិសុខជាតិ អនុប្រធានទី ២

៤-លោក វរសេនីយ៍ទោ **វឿន សារុន** តំណាងកងរាជអាវុធហត្ថជាតិ អនុប្រធានទី ៣

៥-លោក វរសេនីយ៍ត្រី **ហៀង ប៊ុនឌឿន** តំណាងការិយាល័យទី ៤នៃអគ្គសេនាធិការ ក្រសួងការពារជាតិ ជាសមាជិក

៦_លោក វរសេនីយ៍ត្រី អ៊ុក សារ៉ា ផ្នែកចរាចរផ្លូវគោក ក្រសួងមហាផ្ទៃ សន្តិសុខ ជាសមាជិក

៧_លោក ខឿន សាខុន នាយក្រុមប្រឡងយកប័ណ្ណបើកបរ និងយន្តការីនាវា នៃការិយាល័យត្រួតពិនិត្យយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៨_លោក សាន សុន នាយក្រុមផ្ទេរកម្មសិទ្ធិ និងផ្លាកលេខជលយាននៃការិយាល័យ ត្រួតពិនិត្យយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៩_លោក សរ ស៊ីថា សមាជិកគណៈកម្មការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្ត នៃការិយាល័យត្រួតពិនិត្យយានយន្ត ក្រសួងសសាធារណការ និងដឹកជញ្ជូន ជាសមាជិក

ប្រការ ២ : គណៈកម្មការខាងលើមានភារកិច្ច ចុះធ្វើការត្រួតពិនិត្យផ្ទាល់ លើមធ្យោបាយធ្វើដំណើរគ្រប់ប្រភេទ ទាំងផ្លូវគោក និងផ្លូវទឹក ដែលធ្វើចរាចរប្រកបមុខរបរមិនស្របច្បាប់ ។

-សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៣ : លោកអគ្គនាយក លោកប្រធានមន្ទីរ លោកប្រធានការិយាល័យត្រួតពិនិត្យយានយន្ត ព្រមទាំងអស់លោកដូចប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់តាមខ្លឹមសារនៃសេចក្តីសំរេចខាងលើ ។

ប្រការ ៤ : -សេចក្តីសំរេចមុន ដែលផ្ទុយនិងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : -សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
អនុរដ្ឋលេខាធិការ
នូ សាំខន

***

៦. ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០០៨ បធ.ប្រក
ស្តីពីការតែងតាំង បជិត្តាហាកៈមន្ទីរប្រៃសណីយ៍
និងទូរគមនាគមន៍

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ១៩៩៤ និងប្រកាសអោយប្រើ នៅថ្ងៃទី ២០ កក្កដា ១៩៩៤

-បានឃើញប្រកាសលេខ ០៨២.ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំរចនាសម្ព័ន្ធមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខ្សែរយៈបណ្តោយគ្រប់ខេត្ត-ក្រុង

-បានឃើញ សំណូមពរ និង ការឯកភាពរបស់អភិបាលខេត្ត កណ្តាល លេខ ៥១៣ .សណ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៤

-ពិនិត្យសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០១ រូបដូចមានឈ្មោះខាងក្រោមជា បជិត្តាហាកៈរងនៃមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តកណ្តាល ។

១.លោក **ស្រ៊ុន គង់** បជិត្តាហាកៈរង

ប្រការ ២ : បដិហារកៈរងមានភារកិច្ចគ្រប់គ្រងដឹកនាំ និងទទួលខុសត្រូវលើការងារសេវាកម្ម អាជីវកម្ម ប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំងខេត្ត-ស្រុក ជូនមុខអោយក្រសួង ។

ប្រការ ៣ : នាយកខុទ្ទកាល័យ,អធិការដ្ឋាន,នាយកដ្ឋានផែនការ គណនេយ្យហិរញ្ញវត្ថុ, នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ,នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០០៩ ចបប្រក

-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-០៣-៨៧ ស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញពាក្យស្នើសុំរបស់អ្នកស្រីវង្សថានី ចុះថ្ងៃទី ១៧-០១-៩៥ ។

សំរេច

ប្រការ ១ : -អនុញ្ញាតអោយអ្នកស្រី **វង្ស ថានី** បន្តការប្រើប្រាស់ប្រព័ន្ធវិទ្យុទាក់ទងប្រភេទ វេហាស់ អែសចល័តនិងបំពាក់ជូនដល់បុគ្គលិកដូចខាងក្រោម :

-វិទ្យុម៉ាក កិន វូតតេអិម ២៤១ អា លេខសេរី ៤០២០០៣៥៤ តាំងនៅផ្ទះលេខ ៩៧ អឺ០ ផ្លូវ ៤៤០ សង្កាត់ទួលទំពូង ខ័ណ្ឌចំការមន ។

-លោក **អ៊ាភ មករា** វិទ្យុម៉ាកតោស ២៨ លេខសេរី ០៣៧៧០ ។

ប្រការ ២ : -ឋបនភ័ណ្ឌវិទ្យុមាន :

ក-វិទ្យុម៉ាកកិនវូតតេអិម ២៤១ អា ប្រើអង់តែនហ្វអេ កំលាំងផ្សាយ ៥០ វ៉ាត់ ចំនួន ០១ គ្រ

-វិទ្យុម៉ាក តេហាស់ ២៨ កំលាំងផ្សាយ ០៥ វ៉ាត់ ចំនួន ០១ គ្រ ។

ខ_ទីតាំងនិងទិសដៅទាក់ទង : ចល័តក្នុងក្រុងនិងផ្ទះលេខ ៩៧ អឺ០ ផ្លូវ ៤៤០ សង្កាត់ទួលទំពូង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

គ_រលកធាតុអាកាសទាក់ទង : ១៣៩,៩៧ MHZ et ១៤១,២៥០ MHZ

ឃ_សញ្ញាហៅទាក់ទង : កុក១................កុក២

ប្រការ ៣ : នាយកខុទ្ទកាល័យ នាយកដ្ឋានប្រៃសណីយ៍ ប្រធានអធិការកិច្ច នាយកដ្ឋានផែនការគណៈនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និងនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិទទួលបន្ទុកពិនិត្យបច្ចេកទេសនិងអ្នកស្រី វង្ស ថានី ត្រូវអនុវត្តនូវរាល់បទបញ្ញត្តិជាធរមាន ។

ប្រការ ៤ : _សាម៉ីអង្គភាពត្រូវដាក់ពាក្យសុំបន្តបើផុតកំណត់ច្បាប់ឬមានការកែប្រែបនភ័ណ្ឌវិទ្យុដោយប្រការណាមួយ ។

ប្រការ ៥ : _ប្រកាសនេះមានប្រសិទ្ធភាពរយៈពេលមួយ " ០១ " ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១០ បធប្រក

_រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥_០៣_៨៧ ស្តីពី ប្រៃសណីយ៍ និងទូរគមនាគមន៍ ។

_បានឃើញពាក្យស្នើសុំផ្អាកឈប់ប្រើប្រាស់របស់អ្នកស្រី វង្ស ថានី ចុះថ្ងៃទី ១៧_០១_៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតិអោយអ្នកស្រី **វង្ស ថានី** ផ្អាកឈប់ប្រើប្រាស់ប្រព័ន្ធវិទ្យុទាក់ទងប្រភេទ វេហាស់អែហ្វ ចំនួន ០៤ គ្រ ។

ប្រការ ២ : ប្រកាសលេខ ០៦៦ ប្រកបទ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៣ ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ នាយកដ្ឋានប្រៃសណីយ៍ ប្រធានអធិការកិច្ច នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិត្រូវទទួលបន្ទុកពិនិត្យបច្ចេកទេស និង អ្នកស្រី វង្ស ថានី ត្រូវអនុវត្តនូវរាល់បទបញ្ញត្តិជាធរមាន ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ យុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១១ បធប្រក

-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ០៥-០៣-៨៧ ស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញពាក្យស្នើសុំរបស់លោក សៀង អ៊ី ចុះថ្ងៃទី ១៣-០១-៩៥ ។

សំរេច

ប្រការ ១ : -អនុញ្ញាត្តិអោយ លោក **សៀង អ៊ី** ផ្លាស់ប្តូរទីតាំងបរិក្ខារវិទ្យុ ០១ គ្រ ពីផ្ទះលេខ ០៨ អ៊ី០ ផ្លូវ ៣៨៩ សង្កាត់ទឹកល្អក់ ទី១ ខ័ណ្ឌទួលគោក មកតាំងនៅផ្ទះលេខ ៣៨៥ អ៊ី០ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា បរិក្ខារវិទ្យុមាន : វិទ្យុហាស់អែហ្វម៉ាកអ៊ីកូម ៧២៥ លេខសេរី ២២៧២៧ តាំងនៅផ្ទះលេខ ៣៨៥ អ៊ី០ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខ័ណ្ឌ ៧មករា ។ វិទ្យុម៉ាកយ៉ាអ៊ីស៊ូ លេខសេរី ២២៦៣០ តាំងនៅផ្ទះលេខ ៥៨ មណ្ឌល២ សង្កាត់២ ខ័ណ្ឌមិត្តភាពក្រុងព្រះសីហនុ ។ វិទ្យុវហាស់អែហ្វ :លោក **សៀង អ៊ី** លេខ ៤០៦០៩១៦៩ លោក **ហេង សុភក្រ្ត** វិទ្យុម៉ាកកិនវូត លោក **លី ម៉េង** វិទ្យុលេខសេរី ៤០៦០៩១៤២ លោក **ឈាង ម៉ិនជុន** វិទ្យុម៉ាកកិនវូត លោក **លី ណាំ** វិទ្យុលេខសេរី ៤០៦០៨៥៦៤ ។

ប្រការ ២ : _ប្រកាសលេខ ០៩៤ ប្រក តប បទក ចុះថ្ងៃទី ២២_០២_៩៣ ទុកជានិរាករណ៍ ។

ប្រការ ៣ : _បំពងកំណត់វិទ្យុមាន :

ក_វិទ្យុហាស់ហ្វ្រេកង់អ៊ីកូម ៧២៥ ប្រើអង់តែនឌីប៉ូលកំលាំងផ្សាយ ១០០វ៉ាត់ ចំនួន ០២ គ្រ

_វិទ្យុវ៉ាក់គីតូគី ២វេអា កំលាំងផ្សាយ ០៥វ៉ាត់ ចំនួន ០៥ គ្រ ។

ខ_ទីតាំងនិងទិសដៅទាក់ទង :ភ្នំពេញផ្ទះលេខ ៣៨៥ អឺ០ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ទាក់ទងជាមួយក្រុងព្រះសីហនុនិងទាក់ទងចល័តក្នុងរាជធានីភ្នំពេញ ។

គ_រលកធាតុអាកាសទាក់ទង :HF ៥,២២៦ MHZ et ៧,៣៦៨ MHZ VHF ១៤៨,១២៥ MHZ et ១៥២,១២៥ MHZ

ឃ_សញ្ញាហៅទាក់ទង សេក១.........................សេក៣

ប្រការ ៤ : _នាយកខុទ្ទកាល័យ នាយកដ្ឋានប្រៃសណីយ៍ ប្រធានអធិការកិច្ច នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិត្រូវទទួលបន្ទុកពិនិត្យបច្ចេកទេស និង លោក សៀង អ៊ី ត្រូវទទួលអនុវត្តនូវរាល់បទបញ្ញត្តិជាធរមាន ។

ប្រការ ៥ : _សាមីអង្គភាពត្រូវដាក់ពាក្យសុំបន្តបើផុតកំណត់ច្បាប់ឬមានការកែប្រែបំពងកំណត់វិទ្យុដោយប្រការណាមួយ ។

ប្រការ ៦ : _ប្រកាសនេះមានប្រសិទ្ធភាពរយៈពេលមួយឆ្នាំដោយគិតពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

៧. ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២១/៩៥ ក.ធ.ស ប្រក

ស្តីពីការតែងតាំង មន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើត ទីស្តីការក្រសួងធម្មការ និង សាសនា ដែលប្រកាស អោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ឆ្នាំ ១៩៩២

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

-សំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ :តែងតាំង :

១-លោក **សេង ណាក** បច្ចុប្បន្នប្រធានការិយាល័យបុគ្គលិក ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ចទទួលបន្ទុកការិយាល័យបុគ្គលិក ។

២-លោក **ក្រេស សារ៉ុម** បច្ចុប្បន្នប្រធានការិយាល័យរបៀប ជាអនុប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ចទទួលបន្ទុកការិយាល័យរបៀប ។

៣-លោក **ទុំ ណារ៉ន់** បច្ចុប្បន្នអនុប្រធានការិយាល័យគណនេយ្យ ជាប្រធានការិយាល័យទទួលបន្ទុកគណនេយ្យ ។

៤-អ្នកស្រី **ហ៊ុយ គន្ធា** បុគ្គលិកការិយាល័យផែនការ ហិរញ្ញកិច្ច ជាអនុប្រធានការិយាល័យផែនការ ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច និង អស់លោកដូចមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីប្រកាសនេះអោយបានល្អប្រសើរ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៥ កធស ស្តីពីការលុបចោលជាស្ថាពរនូវ សេចក្តីសំរេចលេខ ២១ កធស ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

សំរេច

ប្រការ ១ : ប្រកាសលុបចោលជាស្ថាពរនូវសេចក្តីសំរេចលេខ ២១/៩៥ កធស.បុគ្គ. ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំង មន្ត្រីរាជការ ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច និង សាមុីខ្លួន ត្រូវអនុវត្តសេចក្តីប្រកាសនេះ អោយបានល្អប្រសើរ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ័ត្ន

* * *

៨. រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៧៥ ប្រក.មស.បល
ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ រស.នកត ១០៩៤.៤៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងប្រកាសលេខ ៤៦០ ប្រក.មស.បល ចុះថ្ងៃទី ១៣-១០-១៩៩៤

-បានឃើញការចាំបាច់របស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

ប្រការ ១ : បញ្ចូលលោក ប្រាក់ ភា ក្នុងក្របខ័ណ្ឌនាយកដ្ឋាន និតិកម្ម នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ប្រការ ២ : លោក ប្រាក់ ភា ត្រូវទទួលកាំប្រាក់បៀវត្ស ខ III. ១ ស្មើ ២២.០០០រ០០ ក្នុងមួយខែ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋាន និតិកម្ម និងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៣៦ ប្រក.មស.បល
ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០-៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- យោងប្រកាសលេខ ៨៦៣ ប្រក.មស.បល ចុះថ្ងៃទី ១៧-១០-១៩៩៤
- បានឃើញការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

សំរេច

ប្រការ ១ : បញ្ចូល កញ្ញា **ណែម ចណ្ណាទី** កើតថ្ងៃទី ២៥-០៧-១៩៧៤ ក្នុងបញ្ជីក្របខ័ណ្ឌនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ប្រការ ២ : កញ្ញា **ណែម ចណ្ណាទី** ត្រូវទទួលកាំប្រាក់បៀវត្ស ខ ııı . ១ ស្មើនឹងទឹកប្រាក់ ២២.០០០៛ ក្នុងមួយខែ ។

ប្រការ ៣ : លោក នាយកខុទ្ទកាល័យនិងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៨៨ ប្រក.មស.បល
ស្តីពីការអនុញ្ញាតអោយផ្អាកការងារដោយ
គ្មានបៀវត្ស

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញសារាចរណែនាំលេខ ០៣ សរ ចុះថ្ងៃទី ០៥ -០៣-១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស៊ីវិល ផ្អាកការងារមួយរយៈដោយគ្មានបៀវត្ស ។

-ពិនិត្យពាក្យស្នើសុំរបស់សាម៉ីខ្លួន ចុះថ្ងៃទី ០៤-០១-១៩៩៥ ។

-ពិនិត្យលិខិតធានាអះអាងរបស់នាយកដ្ឋាន អាណាព្យាបាល ចុះថ្ងៃទី ១៣-០១-១៩៩៥ ធានាអះអាងថា ការផ្អាកការងារនេះ មិនប៉ះពាល់ដល់ដំណើរការ ការងាររបស់នាយកដ្ឋាន ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **យស់ សុភ្ជា** ផ្អាការងារដោយគ្មានបៀវត្ស រយៈពេលប្រាំមួយខែ គិតចាប់ពីថ្ងៃទី ០១-០១-១៩៩៥ ដល់ថ្ងៃទី ០១-៧-១៩៩៥ ។

ប្រការ ២ : ក្របខ័ណ្ឌលោក **យស់ សុភ្ជា** ត្រូវរក្សាទុកក្នុងអង្គភាពរបស់ខ្លួនដដែល ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានក្របខ័ណ្ឌ និង សាម៉ីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

***

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៣៧២ រៀល